រាជបណ្ឌិត្យសភាកម្ពុជា

# ទេសន្តរប្រវេសន៍ពលករខ្មែរ

# Migration of Cambodian Workers

សុខ ឧស្សាហ៍

និក្ខេបបទបណ្ឌិតនីតិសាស្ត្រ

ឯកទេស នីតិឯកជន

ភ្នំពេញ ២០១៦

រាជបណ្ឌិត្យសភាកម្ពុជា

# ទេសន្តរប្រវេសន៍ពលករខ្មែរ

# Migration of Cambodian Workers

សុខ ឧស្សាហ៍

និក្ខេបបទបណ្ឌិតនីតិសាស្ត្រ

ឯកទេស នីតិឯកជន

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិតសភាចារ្យ ខ្លូត ធីតា
សាស្ត្រាចារ្យណែនាំរង ៖ បណ្ឌិត ស៊ិន សូត

ភ្នំពេញ ២០១៦

# មាតិកា

**ទំព័រ**


មាតិកា ....................................................................................................i
ឧទ្ទិសស្នាដៃ ..............................................................................................iv
សេចក្ដីថ្លែងអំណរគុណ ..................................................................................v
អំណះអំណាង ............................................................................................vii
អក្សរកាត់ (ប្រើក្នុងនិក្ខេបបទនេះ) ..........................................................viii
មូលន័យសង្ខេប ..........................................................................................x
Abstract ..................................................................................................xiii
សង្ខេបនិក្ខេបបទ .......................................................................................xvi
Thesis Abstract .......................................................................................xxii
អារម្ភកថា ...............................................................................................xxix


## សេចក្ដីផ្ដើម


១-លំនាំបញ្ហានៃការស្រាវជ្រាវ ......................................................................១
២-ចំណោទបញ្ហានៃការស្រាវជ្រាវ ....................................................................២
៣-គោលបំណងនៃការស្រាវជ្រាវ ......................................................................៣
៤-ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ......................................................៣
៥-វិធីសាស្ត្រស្រាវជ្រាវ ..................................................................................៣
៦-សារប្រយោជន៍នៃការស្រាវជ្រាវ ....................................................................៤
៧-រចនាសម្ព័ន្ធនិក្ខេបបទ ...............................................................................៤


## ជំពូកទី១
## ទស្សនាទាននៃទេសន្តរប្រវេសន៍ពលករ


១.១-ទេសន្តរប្រវេសន៍ពលករ .........................................................................៥
១.១.១-និមយន័យ ......................................................................................៥
១.១.២-ប្រវត្តិចំណាកស្រុកនៅលើពិភពលោក ...................................................៧
១.២-ចំណាកស្រុកមុនសម័យទំនើប .................................................................១៧
១.៣-ចំណាកស្រុកបែបទំនើប ........................................................................២១
១.៣.១-ឧស្សាហូបនីយកម្មនិងការងើបឡើងនៃជាតិនិយមឬចក្រពត្តិនិយម ..................២១
១.៣.២-សង្គ្រាមពិភពលោកនិងវិបាក ..............................................................២២
១.៣.៣-ទេសន្តរប្រវេសន៍ពលកម្មនាសតវត្សរ៍ទី២១ ............................................២៥

១.៤-ប្រវត្តិពលករចំណាកស្រុកកម្ពុជា ........ ២៧
១.៥-កត្តាផ្សេងៗនៃចំណាកស្រុក ........ ៣០
  ១.៥.១-ទស្សនៈជាប្រវត្តិសាស្ត្រ ........ ៣០
  ១.៥.២-កត្តាជំរុញនិងអូសទាញ ........ ៣១
  ១.៥.៣-មុខងារនៃចំណាកស្រុក ........ ៣៤
  ១.៥.៤-មធ្យោបាយ ........ ៣៤
  ១.៥.៥-របៀបចេញ ........ ៣៤
  ១.៥.៦-ប្រកចេញ ........ ៣៥
១.៦-ក្របខ័ណ្ឌច្បាប់និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងក្រុមហ៊ុនបញ្ជូនពលករ ........ ៣៥
  ១.៦.១-និយ័តកម្មច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ/ការបង្កើតប្រព័ន្ធស្របច្បាប់ ........ ៣៥
  ១.៦.២-ស្ថាប័នសំខាន់ៗសម្រាប់ជ្រើសរើសពលករ ........ ៣៨
  ១.៦.៣-ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារជ្រើសរើសពលករឬ
  ទីភ្នាក់ងារជ្រើសរើសឯកជន ........ ៣៩
  ១.៦.៤-ការជ្រើសរើសនិងណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ ........ ៤២
  ១.៦.៥-កម្មវិបាក កម្ពុជា-ម៉ាឡេស៊ី ........ ៤៦
  ១.៦.៦-ដំណើរចាកចេញរបស់ស្ត្រីកម្ពុជាធ្វើការតាមផ្ទះ
  (ចាប់ពីការជ្រើសរើសរហូតដល់មាតុភូមិនិវត្តន៍) ........ ៤៩
  ១.៦.៧-សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការនិង
  ការធ្វើមាតុភូមិនិវត្តន៍ ........ ៥១

## ជំពូកទី២
## ប្រសិទ្ធភាពការងាររបស់ពលករចំណាកស្រុក

២.១-អាទិការណ៍នៃចំណាកស្រុកពលករខ្មែរ ........ ៦០
  ២.១.១-ស្ថានភាពគ្រួសារ ........ ៦០
  ២.១.២-ស្ថានភាពប្រជាសាស្ត្រ ........ ៦០
  ២.១.៣-និកម្មភាព ........ ៦២
២.២-ស្ថានភាពនៃទេសន្តរប្រវេសន៍ចាប់ពីឆ្នាំ២០០៧ដល់បច្ចុប្បន្ន ........ ៦២
២.៣-លក្ខខណ្ឌជ្រើសរើសពលករនិងការចេញដំណើរ ........ ៦៤
  ២.៣.១-ការប្រកាសផ្សព្វផ្សាយ-ជ្រើសរើសពលករ ........ ៦៤
  ២.៣.២-ការចុះកិច្ចសន្យាជាមួយពលករ/ការជ្រើសរើសពលករ ........ ៦៦
  ២.៣.៣-ការអភិវឌ្ឍមុខរបរនិងការងារ ........ ៧៩
  ២.៣.៤-យន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍ ........ ៨៣
  ២.៣.៥-អធិការកិច្ចទីភ្នាក់ងារជ្រើសរើស ........ ៨៤

២.៣.៦-បទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ....................................................៨៦
២.៣.៧-ភ្នាក់ងារជ្រើសរើសពលករនិងការងាររបស់ពលករកម្ពុជា
នៅប្រទេសម៉ាឡេស៊ី ....................................................................................................៩០
២.៣.៨-ការសម្របសម្រួលដល់ពលករដែលចូលធ្វើការងារខុសច្បាប់
ក្នុងប្រទេសថៃ .............................................................................................................៩៩
២.៤-យន្តការនៃចំណាកស្រុក .......................................................................................៩៩
២.៥-លក្ខខណ្ឌច្បាប់នៃការទូទាត់ប្រាក់ខែ ..................................................................១០២
២.៦-និយោជកនិងការងារក្នុងប្រទេសម៉ាឡេស៊ី ..........................................................១០៨
២.៧-បុគ្គលភាពគតិយុត្តរបស់និយោជក .....................................................................១០៩
២.៨-ការផ្ញើមាតុភូមិនិវត្តន៍មកកម្ពុជា .........................................................................១១១
២.៩-កិច្ចការពារសិទ្ធិពលករចំណាកស្រុកនៅអាស៊ាន ...................................................១១២
២.១០-លំហូររូបិយប័ណ្ណនៅអាស៊ីនិងប៉ាស៊ីហ្វិក .........................................................១១៥

## ជំពូកទី៣
## វិចារណកម្មពលករចំណាកស្រុក

៣.១-វិសទិសភាពវិស័យការងារនិងបទដ្ឋានគតិយុត្ត .........................................................១២១
៣.២-នីត្យានុកូលភាពរបស់ក្រុមហ៊ុនគ្មានអាជ្ញាប័ណ្ណ ...................................................១២៥
៣.២.១-ប្រភេទនៃកិច្ចសន្យា ...................................................................................១២៦
៣.២.២-ភាពមិនប្រក្រតីនៃការបណ្តុះបណ្តាល ............................................................១២៦
៣.៣-សុវត្ថិកម្មលក្ខខណ្ឌការងារពលករចំណាកស្រុកដោយសមាគមអាស៊ាន .....................១២៧
**សន្និដ្ឋាន** ...................................................................................................................១៣២
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# មូលន័យសង្ខេប

ទេសន្តរប្រវេសន៍ដើម្បីការងារ គឺជាប្រពៃណីមួយនៅទីកន្លែងជាច្រើននៅក្នុងមហាអនុតំបន់-ទន្លេមេគង្គ។ ជនណាដែលរស់នៅតាមព្រំដែនអាចឆ្លងកាត់ព្រំដែនចូលទៅក្នុងប្រទេសជិតខាងរាល់ថ្ងៃ ទៅកាន់កន្លែងការងារនិងសហគមន៍ដែលខ្លួនបានធ្វើការអស់រយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែ ចលនាដែលណែនាំខុសនិងដោយពុំមានការគ្រប់គ្រងនេះបាននាំឱ្យប្រជាជនស្ថិតក្នុងហានិភ័យយ៉ាងធំធេងដោយទទួលរងការកេងប្រវ័ញ្ចឬក្លាយជាជនរងគ្រោះដោយជនល្មើសជួញដូរមនុស្សដែលបានសន្យាជាមួយពួកគេថា មានការងារប្រសើរជាងមុននៅក្នុងឧស្សាហកម្មឬកន្លែងដទៃទៀតនៅក្នុងប្រទេសទទួល។

ចំណាកស្រុកជាបញ្ហាមួយដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ការកើនឡើងយ៉ាងខ្លាំងជាលក្ខណៈពហុប្រភេទនៃចំណាកស្រុកបានទាក់ទាញចំណាប់អារម្មណ៍ពីរាជរដ្ឋាភិបាលកម្ពុជាដែលទទួលស្គាល់ផលប៉ះពាល់គោលនយោបាយរយៈពេលវែងសម្រាប់ចំណាកស្រុក។ ចំណាកស្រុកទោះបីជាទៀងទាត់ក្តីឬមិនទៀងទាត់ក្តី គេដឹងថា ជាវិធានការបណ្តុះអាសន្នក្នុងប្រទេសមួយដែលឱកាសធ្វើការងារមានកម្រិតទាប។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះត្រូវឆ្លើយតបទៅនឹងសំណួរស្រាវស្រាវដូចខាងក្រោម ៖

-តើកត្តាអ្វីខ្លះដែលបណ្តាលឱ្យមានលំហូរពលករចំណាកស្រុក ?

-តើការអនុវត្តបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលប្រព្រឹត្តទៅបានល្អប្រសើរកម្រិតណា ?

-តើនីត្យានុកូលភាពរបស់ក្រុមហ៊ុនជ្រើសរើសពលករបានធ្វើឱ្យប្រសើរឡើងដល់ទេសន្តរ-ប្រវេសន៍ពលករដូចម្តេចខ្លះ ?

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងយ៉ាងសំខាន់ក្នុងការការពារ ការបង្រ្កាបនិងទប់ស្កាត់ទេសន្តរប្រវេសន៍ពលករដែលតែងតែកើតមានឡើងជាញឹកញាប់នៅក្នុងសង្គមខ្មែរយើងបច្ចុប្បន្ន ដែលការសិក្សានេះមានវត្ថុបំណងសិក្សាស្រាវជ្រាវពី ៖

-ការអនុវត្តបទដ្ឋានគតិយុត្តនៃវដ្តទេសន្តរប្រវេសន៍ពលករខ្មែរ

-ប្រសិទ្ធភាពនៃគោលនយោបាយប្រតិបត្តិនានា

-វឌ្ឍនភាពសេដ្ឋកិច្ចគ្រួសាររបស់ពលករចំណាកស្រុកខ្មែរនិងសមាគមអាស៊ាន។

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ៖

១-មានតែ ៥២ភាគរយ *នៃស្រ្តីបម្រើតាមផ្ទះប៉ុណ្ណោះ ដែលមានវ័យសមស្របសម្រាប់ការងារតាមផ្ទះនៅក្នុងប្រទេសម៉ាឡេស៊ី យោងតាមច្បាប់ទាំងនៅប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី។*

លើសពី ២០ភាគរយ មានអាយុក្រោម ១៨ឆ្នាំ នៅខណៈពេលនៃការបណ្តុះបណ្តាលមុនចេញដំណើរ និង ២៥ភាគរយទៀត គឺមានអាយុពី ១៨-២១ឆ្នាំ។

២-*១៨,២ភាគរយនៃពលករដែលបានជ្រើសរើសជាគំរូសំណាកទ្រាំនឹងស្ថានភាពរំលោភបំពានក្នុងកំលុងពេលបណ្តុះបណ្តាលមុនចេញដំណើរ ហើយពួកគេមិនបានទទួលការបណ្តុះបណ្តាលអ្វីទាំងអស់ដែលពួកគេមានសិទ្ធិទទួលបានក្រោមច្បាប់។*

ច្បាប់កម្ពុជាតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករបណ្តុះបណ្តាលពលករចំណាកស្រុក ស្តីពីប្រព័ន្ធការងារ ទំនៀមទម្លាប់ ប្រពៃណីនិងច្បាប់ជាមូលដ្ឋាននៃប្រទេសគោលដៅ។ ប៉ុន្តែពលករចំណាកស្រុកភាគច្រើនដែលជាគំរូសំណាកបានរាយការណ៍ថា គ្រាន់តែទទួលបានការបណ្តុះបណ្តាលមុនចេញ

ដំណើរតែប៉ុណ្ណោះ គឺលើជំនាញការងារនិងភាសា ហើយការបណ្តុះបណ្តាលជាទូទៅពីវប្បធម៌និងច្បាប់មានតិចតួចបំផុត។ ក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ អ្នកផ្តល់ព័ត៌មានសំខាន់បានរាយការណ៍ថា បានស៊ូទ្រាំនឹងស្ថានភាពនៃការរំលោភបំពាន។ ស្ត្រីចំនួន១៤នាក់ (១៨,២ភាគរយ) បានរៀបរាប់ថា មានការគំរាមកំហែងនិង១៤នាក់ទៀត (១៨,១ភាគរយ) បង្ហាញថា ពួកគេបានបំពានដោយពាក្យសម្តីពីអ្នកបណ្តុះបណ្តាលរបស់ទីភ្នាក់ងារជ្រើសរើសពលករ។

៣-កិច្ចសន្យារបស់ *ទីភ្នាក់ងារជ្រើសរើសពលករកម្ពុជាកម្រនឹងបំពេញទៅតាមតម្រូវការជាអប្បបរមានៃច្បាប់កម្ពុជា*។

ពលករចំណាកស្រុកចំនួន១៤នាក់ក្នុងចំណោម ៧៧នាក់ (១៨,១ភាគរយ)ដែលបានសម្ភាសបានថ្លែងថា ពួកគេមិនបានយល់ពីកិច្ចសន្យាឬផលវិបាកនៃការផ្តាច់កិច្ចសន្យារបស់ពួកគេឡើយ។ ពលករដែលបញ្ជាក់ថា ពួកគេបានយល់ដឹងពីលក្ខខណ្ឌនៃកិច្ចសន្យារបស់ពួកគេ ភាគច្រើនបានបញ្ជាក់ថា ជាការពិតនោះ ពួកគេបានដឹងតែពីរយៈពេលនៃកិច្ចសន្យាប៉ុណ្ណោះ(អ្នកឆ្លើយតបចំនួន៤៣នាក់ឬស្មើនឹង៥៥,៨ភាគរយ)។ ពលករចំនួន១០នាក់ (១០ភាគរយ) បានបញ្ជាក់ថា ពួកគេមិនបានទទួលព័ត៌មានអ្វីពីលក្ខខណ្ឌនៅក្នុងកិច្ចសន្យាឡើយ។

៤-មិន *មានគោលនយោបាយស្តង់ដាឬការកំណត់ការបង់ប្រាក់និងថ្លៃរបស់ទីភ្នាក់ងារជ្រើសរើសពលករទេ។ ចំនួនទឹកប្រាក់សរុប(ទាំងការបង់ប្រាក់និងថ្លៃ)ដែលបង់ឱ្យភ្នាក់ងារជ្រើសរើសពលករ គឺមានតម្លៃចាប់ពី ២.០០០ដុល្លារអាម៉េរិក និង ២.៦៧៦ដុល្លារអាម៉េរិកចំពោះអ្នកបម្រើតាមផ្ទះម្នាក់*។

ពលករចំណាកស្រុកកម្ពុជាក្នុងគំរូសំណាកត្រូវបង់ថ្លៃទៅឱ្យទីភ្នាក់ងារជ្រើសរើសពលកររវាង៨១០ដុល្លារនិង១.២០០ដុល្លារអាម៉េរិក ខណៈពេលដែលថ្លៃបង់ដោយទីភ្នាក់ងារទៅឱ្យនិយោជកម៉ាឡេស៊ី គឺមានតម្លៃរវាង ១.១៩០ដុល្លារនិង១.៥២៩ដុល្លារអាម៉េរិក។ ទោះបីជាយ៉ាងណា ស្ត្រីបម្រើការងារតាមផ្ទះត្រូវគេឃើញថាមានការទទួលខុសត្រូវចំពោះថ្លៃសេវាទាំងនេះ ដែលបង់ដោយនិយោជករបស់ពួកគេ ហើយពួកគេធ្វើការពី ៤-៥ខែទៅ១២ខែដោយពុំមានប្រាក់ឈ្នួលដើម្បីសងបំណុលនេះ។

៥-*ពលករ* ចំនួន៦៨នាក់ (៨៨,៣ភាគរយ) បានរាយការណ៍ថា មាន*ការកាត់ប្រាក់ខែរបស់ពួកគេនិងប្រមាណ* ១/៣នៃអ្នកទាំងនោះ (២០ក្នុងចំណោម៦៨នាក់) រាយការណ៍ថា បានចាញ់បោកដោយសារតែការកាត់នេះ។

ពលករចំនួន១៧នាក់ (២២,១ភាគរយ) មានអារម្មណ៍ថា ពួកគេត្រូវគេកេងប្រវ័ញ្ចខណៈពេលដែលស្ត្រីបម្រើទាំងនេះ ពិតជាមិនបានទទួលប្រាក់ខែតិចជាងស្ត្រីបម្រើដែលគេកេងប្រវ័ញ្ច ហើយពួកគេរកឃើញថាមានភាពមិនស្របគ្នារវាងប្រាក់បៀវត្សដែលបានសន្យាដោយអ្នកជ្រើសរើសនិងទីភ្នាក់ងារ បើធៀបទៅនឹងប្រាក់ខែពិតប្រាកដដែលបានកេងប្រវ័ញ្ច។ អ្នកទាំងឡាយណាដែលបានបញ្ចប់ការងារពេញពីរឆ្នាំក្រោមកិច្ចសន្យានេះ គឺទំនងជានឹងទទួលបានប្រាក់ខែដែលបានសន្យាដោយទីភ្នាក់ងារជ្រើសរើសពលករ តែទោះបីជាយ៉ាងណា ៧៤ភាគរយនៃស្ត្រីបម្រើតាមផ្ទះបានរាយការណ៍ថា ប្រាក់ខែបានទទួលត្រូវពន្យារពេល ៦១ភាគរយនៃអ្នកទាំងនោះពិតជាទទួលបានប្រាក់ខែទាំងអស់របស់ពួកគេ ដែលរក្សាទុកក្នុងរយៈពេលនៃកិច្ចសន្យា ហើយបានទទួលនៅពេលបញ្ចប់កិច្ចសន្យាដែលនេះ គឺរំលោភលើច្បាប់ម៉ាឡេស៊ី។

៦-ច្បាប់កម្ពុជា *ទាក់ទងទៅនឹងការត្រួតពិនិត្យបរិស្ថាននៅកន្លែងធ្វើការនៅក្នុងប្រទេសគោលដៅនៅតែមានភាពមិនច្បាស់លាស់។* មានតែពលករ ៨នាក់ (៧,៧ភាគរយ)*ប៉ុណ្ណោះ ដែលបានរាយការណ៍ថា កន្លែងការងាររបស់ពួកគេមានការត្រួតពិនិត្យ។*

៧- *ទាំងច្បាប់កម្ពុជាទាំងច្បាប់ម៉ាឡេស៊ី យន្តការសម្រាប់ពាក្យបណ្ដឹង ការដោះស្រាយវិវាទនិង/ឬការពឹងផ្អែកលើច្បាប់ គឺមានកំណត់ ដោយមាននីតិវិធីវែងឆ្ងាយតម្រូវឱ្យពលករចំណាកស្រុក។*

៨៥,៧ភាគរយនៃចម្លើយដែលទាក់ទងទៅនឹងពាក្យបណ្ដឹងនិងដំណើរការពាក្យបណ្ដឹងនោះបានបង្ហាញពីលទ្ធផលអវិជ្ជមាន ហេតុនេះទើបពលករចំណាកស្រុកហាក់ដូចជាមិនមានការតវ៉ាពីបរាជ័យនៅក្នុងយន្តការពាក្យបណ្ដឹង។ ពលករចំណាកស្រុកធ្វើការតាមផ្ទះបានផាត់ចេញពីបទបញ្ញត្តិសំខាន់ដែលគ្រប់គ្រងនីតិវិធីបណ្ដឹងនិងការដោះស្រាយក្រោមច្បាប់ការងារម៉ាឡេស៊ី ហេតុដូច្នេះ ទើបពលករចំណាកស្រុកកម្ពុជាបានផ្ដល់នូវការការពារតិចតួចបំផុត។

បច្ចុប្បន្នមានទីភ្នាក់ងារជ្រើសរើសពលករចំនួន២៨ដែលទទួលបានអាជ្ញាប័ណ្ណពី MoLVT ក្នុងការជ្រើសរើសពលករ។ ក្រុមនេះបានរួមបញ្ចូលទាំង MoLVT និងអង្គការក្រៅរដ្ឋាភិបាលចំនួន២ផងដែរ។ ពលករក្នុងគំរូសំណាកនៃស្ត្រីធ្វើការតាមផ្ទះទាំង ៧៧នាក់ដែលបានសម្ភាសសម្រាប់ការសិក្សានេះគឺចុះឈ្មោះបម្រើសេវានៅទីភ្នាក់ងារចំនួន៩។

ទោះបីជាយ៉ាងនេះក្ដី ពលករយើងទាំងបុរស ទាំងស្ត្រីបាននិងកំពុងតែប្រឈមនឹងភាពរងគ្រោះខ្លះធ្លាក់ចូលក្នុងបទល្មើស (អន្តោប្រវេសន៍ខុសច្បាប់ឬធ្វើការដោយខុសច្បាប់) ដែលត្រូវគេចាប់ដាក់ពន្ធនាគារឬផ្ដន្ទាទោស ខ្លះកំពុងត្រូវគេជួញដូរទៅប្រទេសផ្សេងនិងទទួលរងការកេងប្រវ័ញ្ចគ្រប់រូបភាពខាតបង់ពេលវេលា ធនធាន កម្លាំងកាយ ចិត្ត កិត្តិយស សេចក្ដីថ្លៃថ្នូរ ហើយនៅតែធ្លាក់ក្នុងភាពក្រីក្រដែលកំពុងក្លាយជាបន្ទុករបស់រដ្ឋាភិបាលជៀសមិនរួច។

// ABTRACT

Migration for work is a common thing in many places in the Greater Mekong Sub-region. People who are living along the border get into their workplaces in the neighboring countries every day by just crossing the border for many years. However, the movement with the wrong guidance and with no management has led people into the high risk affected by exploitation or become the victims of human trafficking as offenders promising them a better job in the industry sector or somewhere else in destination country.

The emigration is an issue arising in Cambodia. The serious increase in multi-categories of emigration attracted the impression by the Royal Government of Cambodia who acknowledged the impact on the long term policy for emigration. The emigration, however, it is punctual or not punctual, it is realized that constitutes the provision action in a nation with lower employment opportunity. Therefore, such research must reply to the following research questions:

-What factor does cause the flow of emigration manpower?

-How is better juridical standard performance of the Royal Government?

-How is the legality of the manpower recruitment company to better the manpower migration?

Such research aims mainly to protect, vanquish and prevent the manpower migration that always occurred frequently in our current Cambodia society in which such research aims to research on:

-The juridical standard performance of the Cambodian manpower migration life

-Efficiency of the other operational policies

-Household economic progress of the Cambodian emigration manpower and ASEAN Association.

The study shows that:

1- ***Only 52 percent of women serving as the maids have the appropriate age for domestic work in Malaysia, according to the law, both in Cambodia and Malaysia.***

   In addition, more than 20 percent are under 18 years old at the time of pre-departure training and another 25 percent are between the ages of 18-21 years.

2- ***18.2 per cent of the workers who have chosen as the study sample endured with abuse during pre-departure training and they did not get any training even they are entitled under the law.***

Cambodian law requires migrant workers recruitment agency trains the migrants on the work system, custom-tradition and fundamental laws of the destination country. But the majority of samplers reported that they just get only pre-departure training on work skills and language and there is so little on cultural and law training. In these trainings, it has been reporting that there were enduring with abuse. 14 women (18.2%) described the threat and another 14 women (18.1 percent) indicated that they had been abused by words from the recruitment agency's trainers.

3- ***The contract of the recruitment agency rarely meets the minimum requirements of the law.***

14 among 77 interviewed migrant workers (18.1 percent) said they did not understand the contract, or the consequences of the breakdown contract. Workers who said they understand the terms of their contracts, the majority stated that they know only the duration of the contract (43 respondents, or 55.8 per cent). 10 workers (10 percent) indicated that they did not receive any information about the conditions in the contract.

4- ***There is no standard policy or defined pay and recruitment agency fees. The total amount (both payments and fees) paid to recruitment agencies, is between $ 2 000 and $ 2 676 for maid worker.***

Cambodia migrant samplers have to pay the recruitment agency fees between $ 810 and $ 1200, while the price paid by the agency to the Malaysian Employers is between $ 1 190 and $ 1 529. However, it found that female domestic workers are responsible for these fees paid by their employers, and they worked from 4-5 months to 12 months without wages to pay.

5- ***68 workers (88.3 percent) reported that their salary were docked and about 1/3 of them (20 of 68) reported to be cheated by this dock.***

17 workers (22.1 per cent) felt that they are being exploited, while these women really did not get paid less than women who are exploited. It found that there is a discrepancy between the salary promised by recruiters and agencies compared to actual wage which has been exploited. Those who have completed two full years under the contract are likely to get paid as promised by the recruitment agencies. However, 74 percent of maid workers reported that salaries were delayed, 61 percent of those actually get all the pay for the period of the contract which is again to the Malaysia law.

6- *The law related to the environmental monitoring at workplace in the destination countries remains unclear. Only 8 workers (7.7 percent) reported that there is a monitoring at their workplace.*

7- *Both in Malaysia and Cambodia, the complaints and dispute resolution/or reliance on legislation mechanism is limited as migrants have to get through the lengthy procedures.*

85.7 per cent of the answers related to the complaint and its process showing the negative result. Therefore, migrant workers do not seem to have any complains about the failure in complain mechanism. Migrant domestic workers have undermined the main provisions governing complaining procedures and resolving under the Malaysian labor law. Cambodian migrants have therefore provided minimal protection.

Currently, there are 28 recruitment agencies licensing from MOLVT. These include both MOLVT and 2 NGOs. Workers in the sampling of 77 domestic workers were those who were registered in 9 agencies.

However, both men and women migrants are facing with being as the victims. Some, fall into crime (illegal immigrants or illegal workers) that have been imprisoned or punished. Some are being trafficked to other countries suffering from all forms of exploitation and waste the time, resources, strength, honor, dignity, and remain fall into poverty, which turn to be the government's burden inevitably.

# សង្ខេបនិក្ខេបបទ

រាជរដ្ឋាភិបាលកម្ពុជាបន្តរៀបចំតាក់តែងគោលនយោបាយ ស្តីពីការធ្វើចំណាកស្រុក(ទេសន្តរ-ប្រវេសន៍)នៃកម្លាំងពលកម្មកម្ពុជាទៅក្រៅប្រទេសជាមធ្យោបាយមួយដើម្បីបង្កើនកំណើនសេដ្ឋកិច្ចក្នុងស្រុកនិងប្រយុទ្ធប្រឆាំងនឹងនិកម្មភាព។ គោលដៅសំខាន់ៗសម្រាប់ពលករកម្ពុជាមាន ប្រទេសកូរ៉េខាង-ត្បូង ម៉ាឡេស៊ីនិងថៃ។

ចំណាកស្រុកជាបញ្ហាមួយដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ការកើនឡើងយ៉ាងខ្លាំងជាលក្ខណៈពហុប្រភេទនៃចំណាកស្រុកបានទាក់ទាញចំណាប់អារម្មណ៍ពីរាជរដ្ឋាភិបាលកម្ពុជាដែលទទួលស្គាល់ផលប៉ះពាល់គោលនយោបាយរយៈពេលវែងសម្រាប់ចំណាកស្រុក។ ចំណាកស្រុកទោះបីជាទៀងទាត់ក្តីឬមិនទៀងទាត់ក្តី គេដឹងថា ជាវិធានការបណ្តោះអាសន្នក្នុងប្រទេសមួយដែលឱកាសធ្វើការងារមានកម្រិតទាប។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះត្រូវឆ្លើយតបទៅនឹងសំណួរស្រាវស្រាវដូចខាងក្រោម ៖

-តើកត្តាអ្វីខ្លះដែលបណ្តាលឱ្យមានលំហូរពលករចំណាកស្រុក?

-តើការអនុវត្តបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលប្រព្រឹត្តទៅបានល្អប្រសើរកម្រិតណា?

-តើនីត្យានុកូលភាពរបស់ក្រុមហ៊ុនជ្រើសរើសពលករបានធ្វើឱ្យប្រសើរឡើងដល់ទេសន្តរ-ប្រវេសន៍ពលករដូចម្តេចខ្លះ?

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងយ៉ាងសំខាន់ក្នុងការការពារ ការបង្ក្រាបនិងទប់ស្កាត់ទេសន្តរប្រវេសន៍ពលករដែលតែងតែកើតមានឡើងជាញឹកញាប់នៅក្នុងសង្គមខ្មែរយើងបច្ចុប្បន្ន ដែលការសិក្សានេះមានគោលបំណងសិក្សាស្រាវជ្រាវពី ៖

-ការអនុវត្តបទដ្ឋានគតិយុត្តនៃវដ្តទេសន្តរប្រវេសន៍ពលករខ្មែរ

-ប្រសិទ្ធភាពនៃគោលនយោបាយប្រតិបត្តិនានា

-វឌ្ឍនភាពសេដ្ឋកិច្ចគ្រួសាររបស់ពលករចំណាកស្រុកខ្មែរនិងសមាគមអាស៊ាន។

ការសិក្សាស្រាវជ្រាវនេះទទួលលទ្ធផលល្អ យើងបានប្រើទិន្នន័យទី២ គឺទិន្នន័យដែលមានស្រាប់ដូចជា សុន្ទរកថា របាយការណ៍ ព្រឹត្តិបត្រ សារព័ត៌មាន ទស្សនាវដ្តីនិងកាសែតដែលមានប្រភពច្បាស់លាស់។ លើសពីនេះទៀត ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះកាន់តែសុក្រឹតទៀតនោះ ក៏តម្រូវឱ្យមានឯកសារច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងនិក្ខេបបទនេះ ដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង ...។

ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាភាគច្រើនអ្នកនៅតាមស្រុក ភូមិឬនៅជនបទ គឺជាការផ្លាស់ទីខាងក្នុង។ នេះបើយោងតាមវិទ្យាស្ថានជាតិស្ថិតិនៃប្រទេសកម្ពុជា ចំនួនជនអន្តោប្រវេសន៍នៃប្រជាជនកម្ពុជាមានចំនួន៣៥% (៣៥ភាគរយ)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អត្រានៃការធ្វើចំណាកស្រុកបានឱ្យយើងដឹងថា បុរសធ្វើចំណាកស្រុកច្រើនជាងស្ត្រី។ ជនចំណាកស្រុកភាគច្រើនមានវ័យក្មេង (អាយុពី ១៥-២៥ឆ្នាំ) មានអត្រា ៣០% (៣០ភាគរយ)។ កត្តាដែលធ្វើឱ្យពួកគេធ្វើចំណាកស្រុក ពីព្រោះពួកគេមិនមានផ្ទះសម្បែង ដីធ្លីនិងជីវភាពរស់នៅមិនធូរធារ ហេតុដូច្នេះហើយទើបធ្វើឱ្យពួកគេធ្វើចំណាកស្រុកដើម្បីស្វែងរកជីវភាពរស់នៅ (Maltoni, Bruno 2005)។

កម្មករចំណាកស្រុកពីប្រទេសខ្លួនទៅធ្វើការនៅប្រទេសផ្សេងៗដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមខ្លួនគេនិងគ្រួសារ។ ដោយសារតែនៅក្នុងប្រទេសគ្មានការងារធ្វើគ្រប់គ្រាន់និងប្រាក់

ឈ្នួលទាប ទើបពួកគេត្រូវឃ្លាតឆ្ងាយពីប្រទេសកំណើត ដោយមានភាពប្រថុយប្រថានជាមួយនឹងឧប-សគ្គ គ្រោះថ្នាក់និងគ្មានអ្នកជួយការពារសិទ្ធិសេរីភាពនិងជួយដោះស្រាយពេលមានវិវាទកើតឡើង។ នេះគឺមកពីបញ្ហាគោលនយោបាយប្រទេសថៃផ្តល់ប្រាក់ឈ្នួលក្នុង១ថ្ងៃ៣០០បាត ដែលនេះបានអូសទាញកម្លាំងពលកម្មពីប្រទេសកម្ពុជា ឡាវនិងភូមា។ ពីមុនគេធ្វើតែ ៧ខេត្ត/ក្រុងទេ តម្លៃឈ្នួលពលកម្មចំនួន៣០០បាតក្នុង១ថ្ងៃនេះ តែក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលថៃបានឱ្យអនុវត្តទូទាំងប្រទេស។ កត្តាទី២ មកពីប្រាក់ឈ្នួលពលកម្មស្រុកគេថ្លៃ ឯកសិកម្មនៅក្នុងស្រុកជួបបញ្ហាថ្លៃដើមខ្ពស់តែតម្លៃលក់ថោកគ្មានទីផ្សារ ឯប្រជាពលរដ្ឋខ្វះការទទួលបានព័ត៌មានដែលទាំងនេះជាបញ្ហា ដូច្នេះហើយនៅពេលដែលកម្ពុជាធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននោះ រាល់ទំនិញផ្សេងៗនឹងហូរចូលក្នុងប្រទេសខណៈពេលដែលពលករ/កម្មករខ្មែរគ្មានជំនាញពិតប្រាកដដែលមិនអាចប្រកួតប្រជែងនឹងគេបាន។ តែបញ្ហានេះ រដ្ឋាភិ-បាលបាននិងកំពុងកែសម្រួលនីតិវិធីច្បាប់ពលករនិងធ្វើប្រកាសកិច្ចសន្យាពាក់ព័ន្ធនឹងការគ្រប់គ្រងពលករចំណាកស្រុកឱ្យកាន់តែប្រសើរឡើង។

លោក Lee បែងចែកកត្តាដែលបណ្តាលឱ្យមានការធ្វើចំណាកស្រុកចេញជាពីរក្រុម គឺកត្តា-ជំរុញនិងកត្តាអូសទាញ។ កត្តាជំរុញ គឺអ្វីដែលមិនអំណោយផលឬអនុគ្រោះដល់ទីតាំងដែលគេរស់នៅ រីឯកត្តាអូសទាញ គឺជាអ្វីដែលធ្វើឱ្យគេជាប់ចិត្តទៅនឹងតំបន់នោះ។

**កត្តាជំរុញមាន ៖** ការងារមិនគ្រប់គ្រាន់ ឱកាសតិចតួច លក្ខខណ្ឌជំបូង អ្វីដែលនឹងទទួលគ្រោះទុរ្ភិក្សឬគ្រោះរាំងស្ងួត ការភ័យខ្លាចផ្នែកនយោបាយ ភាពជាទាសករឬការបង្ខំឱ្យធ្វើការ សេវាកម្មថែទាំសុខភាពខ្វះខាត ការបាត់បង់សុខដុមរមនា គ្រោះធម្មជាតិ ការគំរាមកំហែងដល់ជីវិត កង្វះខាតសេរីភាពនយោបាយឬសាសនា បញ្ហាបំពុល ខ្វះទីលំនៅ បញ្ហាកម្មសិទ្ធិដី ម្ចាស់ដី ការសម្លុតគំរាម ការប្រកាន់ពូជសាសន៍ ឱកាសក្នុងការរៀបអាពាហ៍ពិពាហ៍ ថ្កោលទោសនិងសង្គ្រាម។

**កត្តាអូសទាញមាន ៖** ឱកាសការងារ លក្ខខណ្ឌរស់នៅល្អ សេរីភាពផ្នែកនយោបាយនិងសាសនា ការងារ ការអប់រំ សេវាថែទាំសុខភាពល្អ បរិយាកាសទាក់ទាញ សន្តិសុខមានសុវត្ថិភាព ទំនាក់ទំនងគ្រួសារ ឧស្សាហកម្មនិងឱកាសល្អក្នុងការរៀបអាពាហ៍ពិពាហ៍។

ប្រភេទនៃចំណាកស្រុក គឺតាមផ្លូវច្បាប់ ៖ តាមរយៈក្រុមហ៊ុនស្របច្បាប់ទៅប្រទេសដែលមានកិច្ចព្រមព្រៀង និង មិនតាមផ្លូវច្បាប់ឬមិនរៀបរយតាមប្រព័ន្ធផ្លូវការឬមិនមានឯកសារស្របច្បាប់។

-ឆ្លងដែនដោយមានឬគ្មានលិខិតឆ្លងដែនឬប័ណ្ណអនុញ្ញាតឆ្លងដែនតែគ្មានការអនុញ្ញាតឱ្យនៅធ្វើការងារក្នុងប្រទេសគោលដៅ

-ទិញប័ណ្ណឆ្លងដែនចូលតាមច្រកអន្តរជាតិ ឬចេញតាមច្រកតំបន់ឬច្រករបៀងមិនផ្លូវការ តាមការណាត់ ការនាំផ្លូវដោយមេខ្យល់ឬដោយមានការឃុបឃិតពីសមត្ថកិច្ចព្រំដែនទាំងសងខាង

-ការងារខ្លះអាចវិលល្ងាចក្នុងកន្លែងជិតៗព្រំដែនខ្លះទៅឆ្ងាយឆ្លងខេត្តហូតរាប់ខែ តែអាចធ្វើទំនាក់ទំនងគ្រួសារនិងត្រឡប់មកផ្ទះបាន ឯខ្លះទៀតនៅយូរឆ្នាំដោយរត់គេចពីកន្លែងមួយទៅកន្លែងមួយនិងត្រូវគេបោកប្រាស់រំលោភបំពាននិងជួញដូរបន្តរហូតដល់ប្រទេសផ្សេងទៀត

-ការផ្តល់ប័ណ្ណអនុញ្ញាតឱ្យធ្វើការងារនៅប្រទេសថៃមានកំណត់ ដូច្នេះមានពលកររាប់ម៉ឺននាក់ដែលនៅលួចលាក់ធ្វើការងារក្នុងប្រទេសថៃដោយគ្មានការអនុញ្ញាតនាំឱ្យប្រឈមនឹងគ្រោះថ្នាក់ការកេងប្រវ័ញ្ចនិងការចោទប្រកាន់អំពីភាពខុសច្បាប់។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងសម្រេចផ្តល់ការអនុញ្ញាតឱ្យនីតិបុគ្គលឯកជននីមួយៗធ្វើជាទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យស្នើសុំ។

ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវចុះនិងអនុវត្តកិច្ចសន្យាជាមួយក្រសួងការងារនិងបណ្តុះ-បណ្តាលវិជ្ជាជីវៈ អំពីកាតព្វកិច្ចនិងនីតិវិធីនៃការជ្រើសរើស ការអប់រំណែនាំ ការតម្រង់ទិស ការបញ្ជូននិងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេសឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមអនុក្រឹត្យ លេខ ១៩០ អនក្រ/បក. ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជននិងបទបញ្ញត្តិពាក់ព័ន្ធនានា (ប្រការ ៣)។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនយើងបាននាំគ្នាធ្វើចំណាកស្រុកនិងឆ្លងដែនទៅធ្វើការនៅប្រទេសក្រៅយ៉ាងគគ្រឹកគគ្រេង មានទាំងទៅតាមប្រព័ន្ធផ្លូវការនិងទាំងតាមប្រព័ន្ធមិនផ្លូវការយ៉ាងអនាធិបតេយ្យនិងពុំមានការគ្រប់គ្រងច្បាស់លាស់។

តាមពិតឱ្យតែពលករធ្វើចំណាកស្រុកខុសច្បាប់ គឺពួកគាត់ត្រូវប្រឈមនឹងហានិភ័យទាំងអស់ តែពេលនេះរដ្ឋាភិបាលយើងបានគិតគូរច្រើនពីការជួយសម្រួលដល់ពលករមិនស្របច្បាប់ឱ្យស្របច្បាប់វិញ។ ក្រៅពីនោះរដ្ឋាភិបាលបានផ្សព្វផ្សាយអប់រំពីអ្វីហៅថា ស្របច្បាប់ មិនស្របច្បាប់និងការទប់ស្កាត់ពិសេស រដ្ឋាភិបាលរៀបចំធ្វើគោលនយោបាយ ធ្វើកិច្ចសន្យាឱ្យទៅជាស្តង់ដាមួយ ហើយដាក់ឱ្យអនុវត្ត គឺរដ្ឋបានធ្វើប្រកាសប្រមាណជាបីរួចហើយ ពាក់ព័ន្ធនឹងការគ្រប់គ្រងពលករចំណាកស្រុកឱ្យបានល្អប្រសើរ។ អង្គការមានដៃគូនៅអាស៊ីខាងត្បូង អាស៊ីខាងកើតរួមទាំងអាស៊ីអាគ្នេយ៍ទាំង ១០ប្រទេស ហើយក៏បានជួយសង្គ្រោះពលករពីប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី កោះតៃវ៉ាន់និងបណ្តាប្រទេសផ្សេងៗទៀតរាប់រយនាក់ហើយ។

ការគាំទ្រដល់ដំណើរការ COMMIT UNIAP ស្វែងរកការសិក្សាបន្ថែមអំពីលទ្ធផលនិងបទ-ពិសោធន៍របស់អតីតស្ត្រីធ្វើការតាមផ្ទះកម្ពុជាដែលធ្លាប់ធ្វើការក្នុងប្រទេសម៉ាឡេស៊ី។ ដើម្បីសម្រេចបានការងារនេះ ក្រុមអ្នកប្រមូលទិន្នន័យរបស់ UNIAP បានសម្ភាសន៍ស្ត្រីចំនួន៧៧នាក់ដែលបានវិលត្រឡប់ពីការធ្វើជាពលករតាមផ្ទះនៅប្រទេសម៉ាឡេស៊ីដែលបានចាកចេញទៅតាមរយៈទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារចំនួន២៨ ដែលមាននៅក្នុងប្រទេសកម្ពុជា។ បន្ថែមទៅនឹងការសម្ភាសពាក់-កណ្តាលទម្រង់ (Semi-structured interview) មានសម្ភាសស៊ីជម្រៅ (In-depth interview) ចំនួន១៦បន្ថែមទៀត ដើម្បីយល់ដឹងពីអ្នកសម្ភាសកាន់តែច្បាស់ដែលទាក់ទងទៅនឹងការរំពឹងទុក បទ-ពិសោធន៍ ទំនាក់ទំនង ថ្លៃនិងផលប្រយោជន៍នៃវិធីធ្វើការងារបែបនេះ។

គេរកឃើញបញ្ហាសំខាន់ៗចំនួន៧ មានដូចខាងក្រោម ៖

-ទី១ ៖ បទពិសោធន៍នៃអ្នកដែលមានអាយុមិនពេញច្បាប់និងមិនស្របច្បាប់ក្នុងការជ្រើសរើស

-ទី២ ៖ ការបណ្តុះបណ្តាលមុនពេលចេញដំណើរ

-ទី៣ ៖ កិច្ចសន្យា

-ទី៤ ៖ បន្ទុកនិងថ្លៃឈ្នួល

-ទី៥ ៖ ប្រាក់ខែពលករធ្វើការតាមផ្ទះ ការកាត់កងនិងការទូទាត់

-ទី៦ ៖ និយោជកនិងទីកន្លែងការងារក្នុងប្រទេសម៉ាឡេស៊ី និង

-ទី៧ ៖ ផ្លូវតវ៉ា ការដោះស្រាយជម្លោះនិងផ្លូវច្បាប់។

ជាសរុប ការចំណាយពេលសម្រាប់ឱកាសនៃការងារតាមផ្ទះជាញឹកញាប់ជាការងារដែលទទួលបានប្រាក់ដោយផ្អែកតាមកិច្ចសន្យារយៈពេល ២ឆ្នាំ ហើយពេលខ្លះ គឺមានរយៈពេលយូរជាងនេះ។ ប៉ុន្តែ

ជាញឹកញយ ប្រាក់ឈ្នួលមិនបានផ្តល់ឡើយ រហូតទាល់តែចប់កិច្ចសន្យាដែលបញ្ហានេះបង្ខំឱ្យស្ត្រីត្រូវស៊ូទ្រាំនឹងស្ថានភាពការងារដែលមានរយៈពេលយូរ ហត់នឿយនិងពេលខ្លះមានការប្រមាថហួសហេតុ ដើម្បីទទួលបានប្រាក់ឈ្នួលទៅតាមការសន្យាដែលនឹងមិនជិតមកដល់ទេ ដរាបណាកិច្ចព្រមព្រៀងពេញលេញមិនបានបញ្ចប់។ ច្បាប់ដែលមានទាំងក្នុងប្រទេសកម្ពុជានិងម៉ាឡេស៊ីផ្តល់នូវការការពារដែលមានដែនកំណត់សម្រាប់ពលករធ្វើការតាមផ្ទះទាំងនេះ ទោះបីថាមានឱកាសជាច្រើនក្នុងការធ្វើឱ្យប្រសើរឡើងក៏ដោយ ដូចជាតាមរយៈកំណែទម្រង់កិច្ចសន្យា ការបង្ហាញពីទំនាក់ទំនងទៅវិញទៅមករវាងពលករនឹងទីភ្នាក់ងារជ្រើសរើសពលករឬនិយោជកនិងនិយោជិតនិងមិនគិតដល់ការគ្របសង្កត់មុនពីកាតព្វកិច្ចរបស់ពលករចំពោះទីភ្នាក់ងារនិងនិយោជិត។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា ៖

១-មានតែ ៥២ភាគរយ*នៃស្ត្រីបម្រើតាមផ្ទះប៉ុណ្ណោះ ដែលមានវ័យសមស្របសម្រាប់ការងារតាមផ្ទះនៅក្នុងប្រទេសម៉ាឡេស៊ី យោងតាមច្បាប់ទាំងនៅប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី*។

លើសពី ២០ភាគរយ មានអាយុក្រោម ១៨ឆ្នាំ នៅខណៈពេលនៃការបណ្តុះបណ្តាលមុនចេញដំណើរ និង ២៥ភាគរយទៀត គឺមានអាយុពី ១៨-២១ឆ្នាំ។ ច្បាប់នៃប្រទេសកម្ពុជាចែងថា បេក្ខជនដែលមានបំណងធ្វើការនៅបរទេសត្រូវតែមានអាយុ ១៨ឆ្នាំ ស្របពេលដែលច្បាប់នៃប្រទេសម៉ាឡេស៊ីចែងថា ពលករបរទេសដែលធ្វើការតាមផ្ទះត្រូវតែមានអាយុពី ២១-៤១ឆ្នាំ។ ទោះបីជាយ៉ាងណា ពលករក្រោមអាយុ ២១ឆ្នាំ មិនមានលក្ខខណ្ឌការងារឬស្ថានភាពរស់នៅអាក្រក់ជាងពលករដែលមានអាយុលើសពី ២១ឆ្នាំនោះដែរ។ ដូច្នេះ ម៉ាឡេស៊ី គួរកត់សម្គាល់ថា ពលករវ័យក្មេងអាយុលើស ២១ឆ្នាំអាចរកប្រាក់បានច្រើនបង្គួរដែរ។

២- *១៨,២ភាគរយនៃពលករដែលបានជ្រើសរើសជាគំរូសំណាកទ្រាំនឹងស្ថានភាពរំលោភបំពានក្នុងកំលុងពេលបណ្តុះបណ្តាលមុនចេញដំណើរ ហើយពួកគេមិនបានទទួលការបណ្តុះបណ្តាលអ្វីទាំងអស់ដែលពួកគេមានសិទ្ធិទទួលបានក្រោមច្បាប់*។

ច្បាប់កម្ពុជាតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករបណ្តុះបណ្តាលពលករចំណាកស្រុក ស្តីពីប្រព័ន្ធការងារ ទំនៀមទម្លាប់ ប្រពៃណីនិងច្បាប់ជាមូលដ្ឋាននៃប្រទេសគោលដៅ។ ប៉ុន្តែ ពលករចំណាកស្រុកភាគច្រើនដែលជាគំរូសំណាកបានរាយការណ៍ថា គ្រាន់តែទទួលបានការបណ្តុះបណ្តាលមុនចេញដំណើរតែប៉ុណ្ណោះ គឺលើជំនាញការងារនិងភាសា ហើយការបណ្តុះបណ្តាលទៅពីវប្បធម៌និងច្បាប់មានតិចតួចបំផុត។ ក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ អ្នកផ្តល់ព័ត៌មានសំខាន់បានរាយការណ៍ថា បានស៊ូទ្រាំនឹងស្ថានភាពនៃការរំលោភបំពាន។ ស្ត្រីចំនួន១៤នាក់ (១៨,២ភាគរយ)បានរៀបរាប់ថាមានការគំរាមកំហែងនិង ១៤នាក់ទៀត (១៨,១ភាគរយ) បង្ហាញថាពួកគេបានបំពានដោយពាក្យសម្តីពីអ្នកបណ្តុះ-បណ្តាលរបស់ទីភ្នាក់ងារជ្រើសរើសពលករ។

៣-កិច្ចសន្យារបស់*ទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា កម្រនឹងបំពេញទៅតាមតម្រូវការជាអប្បបរមានៃច្បាប់កម្ពុជា*។

ពលករចំណាកស្រុកចំនួន១៤នាក់ក្នុងចំណោម ៧៧នាក់ (១៨,១ភាគរយ) ដែលបានសម្ភាសបានថ្លែងថា ពួកគេមិនបានយល់ពីកិច្ចសន្យាឬផលវិបាកនៃការផ្តាច់កិច្ចសន្យារបស់ពួកគេឡើយ។ ពលករដែលបញ្ជាក់ថា ពួកគេបានយល់ដឹងពីលក្ខខណ្ឌនៃកិច្ចសន្យារបស់ពួកគេ ភាគច្រើនគឺបានបញ្ជាក់ថាជាការពិតនោះ ពួកគេបានដឹងតែពីរយៈពេលនៃកិច្ចសន្យាប៉ុណ្ណោះ (អ្នកឆ្លើយតបចំនួន៤៣-

នាក់ ឬ ស្មើនឹង ៥៥,៨ភាគរយ)។ ពលករចំនួន១០នាក់ (១០ភាគរយ) បានបញ្ជាក់ថា ពួកគេមិនបានទទួលព័ត៌មានអ្វីពីលក្ខខណ្ឌនៅក្នុងកិច្ចសន្យាឡើយ។

*៤-មិនមានគោលនយោបាយស្តង់ដាឬការកំណត់ការបង់ប្រាក់និងថ្លៃរបស់ទីភ្នាក់ងារជ្រើស - រើសពលករទេ។ ចំនួនទឹកប្រាក់សរុប (ទាំងការបង់ប្រាក់និងថ្លៃ)ដែលបង់ឱ្យភ្នាក់ងារជ្រើសរើសពលករ គឺមានតម្លៃចាប់ពី ២.០០០ដុល្លារនិង២.៦៧៦ដុល្លារចំពោះអ្នកបម្រើតាមផ្ទះម្នាក់។*

ពលករចំណាកស្រុកកម្ពុជាក្នុងគំរូសំណាកត្រូវបង់ថ្លៃទៅឱ្យទីភ្នាក់ងារជ្រើសរើសពលកររវាង ៨១០ដុល្លារនិង១.២០០ដុល្លារអាមេរិក ខណៈពេលដែលថ្លៃបង់ដោយទីភ្នាក់ងារទៅឱ្យនិយោជកម៉ា-ឡេស៊ី គឺមានតម្លៃរវាង ១.១៩០ដុល្លារនិង១.៥២៩ដុល្លារអាមេរិក។ ទោះបីជាយ៉ាងណា ស្ត្រីបម្រើការងារតាមផ្ទះត្រូវគេឃើញថាមានការទទួលខុសត្រូវចំពោះថ្លៃសេវាទាំងនេះដែលបង់ដោយនិយោជករបស់ពួកគេ ហើយពួកគេធ្វើការពី ៤-៥ខែទៅ១២ខែដោយពុំមានប្រាក់ឈ្នួលដើម្បីសងបំណុលនេះ។

៥-ពលករចំនួន៦៨នាក់ *(៨៨,៣ភាគរយ)* បានរាយការណ៍ថា មាន*ការកាត់ប្រាក់ខែរបស់ពួកគេនិងប្រមាណ* ១/៣នៃអ្នកទាំងនោះ *(២០ក្នុងចំណោម៦៨នាក់)* រាយការណ៍ថាបាន*ចាញ់បោកដោយសារតែការកាត់នេះ*។

ពលករចំនួន១៧នាក់ (២២,១ភាគរយ) មានអារម្មណ៍ថា ពួកគេត្រូវគេកេងប្រវ័ញ្ចខណៈពេលដែលស្ត្រីបម្រើទាំងនេះ ពិតជាមិនបានទទួលប្រាក់ខែតិចជាងស្ត្រីបម្រើដែលត្រូវគេកេងប្រវ័ញ្ច ហើយពួកគេ រកឃើញថាមានភាពមិនស្របគ្នារវាងប្រាក់បៀវត្សដែលបានសន្យាដោយអ្នកជ្រើសរើសនិងទី-ភ្នាក់ងារ បើធៀបទៅនឹងប្រាក់ខែពិតប្រាកដដែលបានកេងប្រវ័ញ្ច។ អ្នកទាំងឡាយណាដែលបានបញ្ចប់ការងារពេញពីរឆ្នាំក្រោមកិច្ចសន្យានេះ គឺទំនងជានឹងទទួលបានប្រាក់ខែដែលបានសន្យាដោយទីភ្នាក់-ងារជ្រើសរើសពលករ តែទោះបីជាយ៉ាងណា ៧៤ភាគរយនៃស្ត្រីបម្រើតាមផ្ទះបានរាយការណ៍ថា ប្រាក់ខែបានទទួលត្រូវពន្យារពេល ៦១ភាគរយនៃអ្នកទាំងនោះពិតជាទទួលបានប្រាក់ខែទាំងអស់របស់ពួកគេ ដែលរក្សាទុកក្នុងរយៈពេលនៃកិច្ចសន្យា ហើយបានទទួលនៅពេលបញ្ចប់កិច្ចសន្យាដែលនេះ គឺរំលោភលើច្បាប់ម៉ាឡេស៊ី។

៦-ច្បាប់កម្ពុជា *ទាក់ទងទៅនឹងការត្រួតពិនិត្យបរិស្ថាននៅកន្លែងធ្វើការនៅក្នុងប្រទេសគោល-ដៅនៅតែមានភាពមិនច្បាស់លាស់។* មានតែ*ពលករ* ៨នាក់*(៧,៧ភាគរយ)ប៉ុណ្ណោះ ដែលបានរាយ-ការណ៍ថា កន្លែងការងាររបស់ពួកគេមានការត្រួតពិនិត្យ។*

ស្តង់ដាដែលថា និយោជកម៉ាឡេស៊ីត្រូវតែទទួលបានក្រោមច្បាប់របស់ម៉ាឡេស៊ីដើម្បីជួលអ្នកបម្រើក្នុងផ្ទះក៏មានការកំណត់ផងដែរ។ ស្ថានភាពការងារមិនល្អបានកំណត់អត្តសញ្ញាណដោយការស្រាវជ្រាវនេះតាមរយៈសូចនាករផ្សេងមួយនិងមានការជាប់ទាក់ទងទៅនឹងស្ត្រីបម្រើតាមផ្ទះដែលមិនអាចបំពេញការងារតាមកិច្ចសន្យាពីរឆ្នាំរបស់ពួកគេ ដែលជាញឹកញាប់ទទួលរងនូវផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនិងសន្តិសុខអវិជ្ជមានចំពោះអ្នកបម្រើទាំងនោះ។

៧-ទាំង*ច្បាប់កម្ពុជាទាំងច្បាប់ម៉ាឡេស៊ី យន្តការសម្រាប់ពាក្យបណ្តឹង ការដោះស្រាយវិវាទនិង/ឬការពឹងផ្អែកលើច្បាប់ គឺមានកំណត់ដោយមាននីតិវិធីវែងឆ្ងាយតម្រូវឱ្យពលករចំណាកស្រុក*។

៨៥,៧ភាគរយនៃចម្លើយដែលទាក់ទងទៅនឹងពាក្យបណ្តឹងនិងដំណើរការពាក្យបណ្តឹងនោះ បានបង្ហាញពីលទ្ធផលអវិជ្ជមាន ហេតុនេះទើបពលករចំណាកស្រុកហាក់ដូចជាមិនមានការតវ៉ាអំពីបរាជ័យនៅក្នុងយន្តការពាក្យបណ្តឹង។ ពលករចំណាកស្រុកធ្វើការតាមផ្ទះបានផាត់ចេញពីបទបញ្ញត្តិ

សំខាន់ដែលគ្រប់គ្រងនីតិវិធីបណ្តឹងនិងការដោះស្រាយក្រោមច្បាប់ការងារម៉ាឡេស៊ី ហេតុដូច្នេះ ទើបពលករចំណាកស្រុកកម្ពុជាបានផ្តល់នូវការការពារតិចតួចបំផុត។

បច្ចុប្បន្នមានទីភ្នាក់ងារជ្រើសរើសពលករចំនួន២៨ដែលទទួលបានអាជ្ញាប័ណ្ណពី MoLVT ក្នុងការជ្រើសរើសពលករ។ ក្រុមនេះបានរួមបញ្ចូលទាំង MoLVT និងអង្គការក្រៅរដ្ឋាភិបាលចំនួន២ផងដែរ។ ពលករក្នុងគំរូសំណាកនៃស្ត្រីធ្វើការតាមផ្ទះទាំង ៧៧នាក់ដែលបានសម្ភាសសម្រាប់ការសិក្សានេះគឺចុះឈ្មោះបម្រើសេវានៅទីភ្នាក់ងារចំនួន៩។

យោងតាម NGOs ក្នុងស្រុកបានឱ្យដឹងថា ស្ថានភាពរស់នៅៗមជ្ឈមណ្ឌលបណ្តុះបណ្តាលមានកម្រិតទាប មិនមានអនាម័យនិងចង្អៀត។ NGOs ក៏បានបញ្ជាក់ផងដែរថា អ្នកដែលត្រូវបណ្តុះ-បណ្តាលដែលរស់នៅក្នុងមជ្ឈមណ្ឌលតែងបានរារាំងពីការចាកចេញនិងការផ្តល់នូវអាហារ ទឹកមិនគ្រប់គ្រាន់។ ប្រភពព័ត៌ពីកាសែតផ្សេងទៀត បានឱ្យដឹងផងដែរពីស្ថានភាពអាក្រក់ដែលស្ត្រីបានជួបប្រទះនៅក្នុងមជ្ឈមណ្ឌល រួមទាំងការគំរាមដោយពាក្យសម្តីនិងរាងកាយព្រមទាំងការឃុំឃាំង។

ផ្ទុយទៅនឹងរបាយការណ៍ទាំងនេះព្រមទាំងទស្សនវិស័យរបស់ NGOs ស្ត្រីភាគច្រើនគិតថាស្ថានភាពរស់នៅក្នុងមជ្ឈមណ្ឌលមុនពេលចាកចេញដំណើរ ជាទូទៅគឺមានភាពសមរម្យនិងស្អាត និងបានទទួលចំណីអាហារទឹកគ្រប់គ្រាន់។ ស្ត្រី ៦៧នាក់ (៨៧%) បាននិយាយថាពួកគេបានអនុញ្ញាតឱ្យចាកចេញពីមណ្ឌលបន្ទាប់ពីបានការអនុញ្ញាតទៅតាមការស្នើសុំ។ ទោះបីជាយ៉ាងណា ពលករចំណាកស្រុកចំនួន២០ភាគរយ ពិតជាបាននិយាយថា ពួកគេទទួលការគំរាមកំហែងនិងការប្រមាថដោយពាក្យសម្តីពីសំណាក់អ្នកបណ្តុះបណ្តាលនៅទីភ្នាក់ងារហើយស្ត្រីម្នាក់បានរាយការណ៍ថា គាត់ជួបប្រទះនូវការប្រមាថផ្លូវកាយ។

ការសិក្សាស្រាវជ្រាវរកឃើញថា ក្នុងចំណោមពលករដែលជ្រើសរើសជាសំណាកគំរូចំនួន ៧៧នាក់ ឬ ២២,១ភាគរយ បានស៊ូទ្រាំនឹងស្ថានភាពនៃការបោកបញ្ឆោតការងារ ហើយ ១១នាក់ (១៤,៣%) បានគេជួញដូរ ដោយផ្អែកទៅតាមនិយមន័យនៃពិធីសារ Palermo និងច្បាប់នៃប្រទេសកម្ពុជានិងម៉ាឡេស៊ី។

ការឃុំឃាំងស្ត្រីពលករពីមជ្ឈដ្ឋានឯកជនបានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមជាច្រើនសម្រាប់រដ្ឋាភិបាលនិងអ្នកទទួលខុសត្រូវមួយចំនួនក្នុងការកំណត់និងជួយធ្វើអន្តរាគមន៍ចំពោះករណីនៃការកេងចំណេញការងារនិងការជួញដូរមនុស្ស។ ទោះបីជាយ៉ាងណា យើងសង្ឃឹមថាជាមួយនឹងការចែករំលែករឿងរ៉ាវមួយចំនួននេះ រួមទាំងការយល់ឃើញនិងព័ត៌មានពីស្ត្រីពលករដែលធ្វើមាតុភូមិនិវត្តន៍ដែលមាននៅក្នុងការសិក្សានេះនឹងធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់នឹងអាចដើរតួជាអ្នកសកម្មក្នុងការអនុវត្តអនុ-សាសន៍ដែលនឹងជួយធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រីពលករកម្ពុជារាប់ពាន់នាក់ដែលធ្វើការក្នុងប្រទេសម៉ាឡេស៊ីក្នុងពេលបច្ចុប្បន្ននិងអនាគត។

